# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រកាសពាក្យសច្ចានិរន្តរ៍របស់បងស្រីពីររូបនៅបឹងទំពុន
# ថ្ងៃទី ១៤ មករា ២០១៧

អត្ថបទទី១៖ រម ១០,១៣-១៨
ដំណឹងល្អ៖ មថ ៦,២៥-៣៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ បងស្រីប្រធានក្រុមបងស្រីឧបការគុណ បានជ្រើសរើសបងស្រីម៉ារីម៉ាដាឡា ឌិន ចន្ថា និងបងស្រីអានម៉ារី ខាយ ដានី ដើម្បីធ្វើជាបងស្រីអស់មួយជីវិត ណែនាំឲ្យព្រះសហាគមន៍របស់យើងចូលជាមួយព្រះសហាគមន៍នៅស្ថានបរមសុខ ដើម្បីកោតសរសើរព្រះជាម្ចាស់។ អត្ថន័យនៃជីវិតរបស់បងស្រីគឺ "**មានស្ត្រីព្រហ្មចារិនីជាច្រើន ដើរតាមគន្លងរបស់ព្រះគ្រីស្តស្របតាមគម្រោងការណ៍របស់ព្រះអង្គ ធ្វើជាសាក្សីរបស់ព្រះយេស៊ូ ហើយព្រះអង្គលើកពួកគេឡើងឲ្យមានឋានៈជាភរិយារបស់ព្រះអង្គ**"។ ថ្ងៃនេះ យើងបានជ្រើសរើសភរិយារបស់ព្រះយេស៊ូពីរនាក់ នេះជាអត្ថន័យដែលយើងទទួលថ្ងៃនេះ នេះជាសញ្ញាសម្គាល់មួយយ៉ាងពិសេសសម្រាប់ពិភពលោក សម្រាប់ព្រះសហាគមន៍យើង និងជាពិសេសសម្រាប់សង្គមកម្ពុជាយើង។ សព្វថ្ងៃនៅប្រទេសអភិវឌ្ឍន៍មួយចំនួនយុវជនយុវនារី ដែលជ្រើសរើសជីវិតជាអ្នកបួសមានចំនួនតិចទៅៗ ដោយសារសង្គមណែនាំឲ្យមនុស្សមើលជីវិតលោកីយ៍ច្រើនពេក ឪពុកម្តាយមានកូនតិចមិនចង់ឲ្យកូនដើរតាមផ្លូវជីវិតជាអ្នកបួស។ ដូច្នេះថ្ងៃនេះ យើងមានសញ្ញាពីរយ៉ាងពិសេស ដែលណែនាំឲ្យសង្គមរបស់យើងអាចភ្ញាក់ស្មារតី បងស្រីទាំងពីរនាក់បានលះបង់ជីវិតទៅជាគ្រួសារមួយ ដើម្បីទៅជាភរិយារបស់ព្រះគ្រិស្ត។ នេះជាសញ្ញាមួយដ៏អស្ចារ្យ ដែលណែនាំឲ្យថ្ងៃនេះយើងជាព្រះសហាគមន៍ដូចជាបើកទ្វារនៃស្ថានបរមសុខ ដើម្បីឲ្យយើងមើលឃើញអ្វីដែលព្រះយេស៊ូគ្រិស្តកំពុងរៀបចំសម្រាប់យើង។ យើងមានបងស្រីពីរនាក់ ដែលលះបង់ជីវិតដើម្បីធ្វើដំណើរទីជាធ្លុងតែមួយជាមួយព្រះយេស៊ូ នេះជាទ្វារនៃស្ថានបរមសុខដែលកំពុងបើកឡើងឲ្យយើងមើលឃើញ។

ថ្ងៃនេះរួមជាមួយបងប្អូនទាំងអស់ យើងមានអំណរសប្បាយដោយសារបងស្រីទាំងពីរ បានលះបង់អ្វីៗទាំងអស់ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូតែម្តង។ អ្វីៗទាំងអស់របស់បងស្រីទាំងពីរនាក់ គឺសម្រាប់ព្រះយេស៊ូគ្រិស្ត សម្រាប់បងប្អូលឯទៀតៗតាមរបៀបរបស់ព្រះយេស៊ូ ដោយដឹងថានៅពេលបងប្អូនឯទៀតៗមានសេចក្តីត្រូវការយើងនៅ នៅពេលបងប្អូនឯទៀតៗកំពង់យំយើងនៅ នៅពេលបងប្អូនរកឃើញពន្លឺសម្រាប់ជីវិតរបស់គេយើងនៅ។ សម្រាប់យុវនារីទាំងអស់ ដែលអង្គុយនៅទីនេះទៅជាការគ្រាស់ហៅមួយដើម្បីគិត តើខ្ញុំធ្វើអ្វីនឹងជីវិតរបស់ខ្ញុំ? នៅពេលយើងអាយុ៨៥ឆ្នាំយើងត្រូវការសួរខ្លួនឯងតើខ្ញុំបានធ្វើអ្វីខ្លះសម្រាប់ជីវិតខ្ញុំ? តើខ្ញុំបានបំពេញអ្វីដែលខ្ញុំសង្ឃឹមនៅពេល

ខ្ញុំនៅក្មេងឬទេ? ពេលយើងឃើញបងស្រីពីរនាក់ដែលនៅក្មេងៗថ្ងៃនេះ ណែនាំឲ្យយើងទាំងអស់មានកម្លាំងដើម្បីគិតថាអនាគតខ្ញុំធ្វើអ្វី? អនាគតខ្ញុំសុខចិត្តលះបង់សម្រាប់ព្រះសហគមន៍ដែលណែនាំឲ្យខ្ញុំមានសុភមង្គលដ៏ពេញលក្ខណៈ ដោយសារខ្ញុំមានស្វាមីពិសេសគឺព្រះយេស៊ូតែម្តង។ ពាក្យសច្ចាទាំងបីដែលបងស្រីនឹងប្រកាស **គឺបងស្រីសុខចិត្តរស់នៅក្នុងជីវិតក្រីក្រ សុខចិត្តរស់នៅក្នុងព្រហ្មចារីធម៌ សុខចិត្តរស់នៅជាអ្នកស្តាប់បង្គាប់** បងស្រីអាចធ្វើបានដោយមើលឃើញរបៀបរបស់លោកយ៉ូហានម៉ាតាំងម៉ូយ ដែលជាស្ថាបនិកក្រុមគ្រួសារឧបការគុណ មានន័យថាទុកទាំងអស់នៅក្នុងដៃរបស់ព្រះជាម្ចាស់។ ទុកចិត្តលើព្រះជាម្ចាស់ ដែលមានឧបការគុណសម្រាប់យើង យើងត្រូវការរស់នៅតាមអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ។ បច្ចុប្បន្ននេះ យើងជាម្ចាស់ជីវិតផ្ទាល់ខ្លួន យើងភ្លេចទំលាក់ជីវិតរបស់យើងទៅក្នុងដៃរបស់ព្រះយេស៊ូ ដែលមានឧបការគុណសម្រាប់យើងពិតមែន។

ទីមួយ រស់នៅក្នុងជីវិតជាអ្នកក្រីក្រ អត្ថបទគម្ពីរដំណឹងល្អ **"កុំឲ្យខ្វល់ខ្វាយដោយពោលថាយើងនឹងមានអ្វីបរិភោគ មានអ្វីស្លៀកពាក់នោះឡើយ ត្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯព្រះបិតាដែលគង់នៅស្ថានបរមសុខព្រះជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ"។** នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ និងជាអ្វីដែលត្រូវដឹកនាំបងស្រីដើម្បីបំពេញពាក្យសច្ចាប្រណិធានទាំងបី។ រស់នៅក្នុងជីវិតជាអ្នកក្រីក្រ នេះមិនមែនជាគោលដៅរបស់បងប្អូនទេ យើងមានអ្នកក្រីក្រនៅក្នុងប្រទេសកម្ពុជាច្រើន និងគេចង់ចេញពីជីវិតនេះ។ អត្ថន័យដែលយើងស្តាប់ថ្ងៃនេះ គឺធ្វើយ៉ាងណាកុំឲ្យយើងជាប់នឹងទ្រព្យសម្បត្តិដែលណែនាំឲ្យវាដឹកនាំជីវិតរបស់យើង ផ្ទុយទៅវិញយើងលះបង់ចោលទាំងអស់ ដោយដឹងថាព្រះជាម្ចាស់ប្រទានអ្វីៗទាំងអស់។ ជីវិតអ្នកក្រីក្រមានន័យថា យើងលះបង់ចោលនៅក្នុងដើម្បីភ្ជាប់ជាមួយព្រះយេស៊ូដែលប្រទានអ្វីៗទាំងអស់ឲ្យយើងពីមួយថ្ងៃទៅមួយថ្ងៃ។

ទីពីរ ថែរក្សាព្រហ្មចារីធម៌ ឆ្នាំនេះយើងចូលនៅក្នុងឆ្នាំនៃគ្រួសារ ជាសញ្ញាមួយយ៉ាងពិសេសដែលបងស្រីសុខចិត្តធ្វើពាក្យសច្ចានិរន្តរ៍ការពារថែរក្សាព្រហ្មចារិនី សម្រាប់ក្រុមគ្រួសារទាំងអស់ សម្រាប់យុវជនយុវនារីទាំងអស់ ដោយដឹងថាសេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់ អាចបំពេញជីវិតរបស់យើងពិមែន ណែនាំឲ្យយើងមានសេចក្តីសុខនិងអំណរសប្បាយនៅក្នុងខ្លួនពិតមែន។ នេះជាសញ្ញាមួយយ៉ាងពិសេស ដែលយើងបានស្តាប់ ដែលយើងបានទទួល និងណែនាំឲ្យយើងអាចគិតថែមទៀតអំពីជីវិតរបស់យើងជាក្រុមគ្រួសារ នៅក្នុងទំនាក់ទំនងដែលយើងបង្កើតរវាងគ្នានឹងគ្នា ជាពិសេសរវាងយើងនឹងព្រះជាម្ចាស់។

ទីបី ស្តាប់បង្គាប់ ពេលយើងធ្វើតាមចិត្តយើងអស់សេរីភាពហើយ ដោយសារយើងឥតបានស្តាប់សម្លេងនៃព្រះសហគមន៍។ សម្លេងរបស់ប្រធានក្រុម សម្លេងរបស់ព្រះសហគមន៍ ជាសម្លេង

របស់ព្រះជាម្ចាស់តែម្តង បើយើងមិនស្តាប់ ថ្ងៃណាមួយណែនាំឲ្យក្នុងចិត្តយើងលែងមានអំណរសប្បាយ ដោយសារយើងមិនបានធ្វើតាមបង្គាប់ដែលណែនាំឲ្យយើងមានសេរីភាពដ៏ពេញលក្ខណៈ។ បងស្រីឧបការគុណនៅក្នុងភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង និងភូមិភាគកំពង់ចាម ដើម្បីចូលនៅក្នុងជីវិត និងស្តាប់សេចក្តីត្រូវការរបស់ព្រះសហគមន៍។ ការត្រាស់ហៅ ស្តាប់បង្គាប់មិនមែនតែម្ខាង ប៉ុន្តែរួមជាមយយព្រះសហគមន៍ យើងអាចរកឃើញផ្លូវដែលព្រះជាម្ចាស់រៀបចំសម្រាប់យើង។ ធ្វើដូចម្តេច កុំឲ្យរចនាសម្ព័ន្ធដែលយើងកំពុងបង្កើតណែនាំឲ្យបងស្រីរៀងៗខ្លួន អស់កម្លាំង អស់សមត្ថភាព ដើម្បីចេញអ្វីដែលគាត់អាចធ្វើបាន និងចេញអំណោយទានដែលគាត់បានទទួលពីព្រះជាម្ចាស់ ដើម្បីបម្រើសេចក្តីត្រូវការរបស់ព្រះសហគមន៍ និងសេចក្តីត្រូវការរបស់សង្គមផង។

ដូច្នេះខ្ញុំអធិដ្ឋាន ដើម្បីឲ្យពាក្យសច្ចាទាំងបីនេះ អាចទៅជាពាក្យសច្ចាដែលណែនាំឲ្យយើងអាចលះបង់ចោលទៅក្នុងដៃរបស់ព្រះជាម្ចាស់ពិតមែន ដូចម្តាយតេរេសា។ ក្រុមបងស្រីមេត្តាករុណាមិនដែលឲ្យខ្ញុំចុះហត្ថលេខាលើគម្រោងការណ៍មួយដើម្បីសុំជំនួញ ក្រុមបងស្រីរស់នៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់ដល់កំពូល។ ក្នុងអត្ថបទទីមួយ **"ប៉ុន្តែឲ្យគេអង្វររកព្រះអង្គ ដូចម្តេចកើតបើគេមិនជឿ ឲ្យគេជឿព្រះអង្គដូចម្តេចកើតបើគេមិនដែលលឺព្រះអង្គមានព្រះបន្ទូល ឲ្យគេលឺដូចម្តេចកើតបើគ្មាននរណាប្រកាស ឲ្យគេប្រកាសដូចម្តេចកើតបើគ្មាននរណាចាត់ឲ្យទៅប្រកាស"** ប៉ុន្តែថ្ងៃនេះព្រះជាម្ចាស់បានចាត់ឲ្យបងស្រីទាំងពីរនាក់ទៅប្រកាសដំណឹងល្អនេះ ដើម្បីឲ្យគេលឺ ពេលគេលឺហើយគេជឿ ពេលគេជឿហើយគេប្រកាសបន្តទៀត និងគេរស់នៅតាមព្រះបន្ទូលដែលណែនាំឲ្យជីវិតទៅជាជីវិតថ្មី។ យើងរស់នៅក្នុងសង្គមមួយ ដែលមានអ្នកមិនស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ច្រើនណាស់ ក្នុងភូមិភាគភ្នំពេញមានមនុស្សជាង៦០០០០០០នាក់ ប៉ុន្តែគ្រីស្តបរិស័ទតែ១៥០០០នាក់។ ពេលមនុស្សម្នាក់ស្តាប់ព្រះបន្ទូលរបស់ព្រហជាម្ចាស់ ធ្វើឲ្យជីវិតរបស់គាត់ទៅជាជីវិតថ្មី។ សម្រាប់បងស្រី ធ្វើដូចម្តេចដើម្បីឲ្យបងប្អូនឯទៀតៗដែលមិនដែលស្គាល់អំពីព្រះជាម្ចាស់អាចស្គាល់នឹងលឺបាន។ អត្ថបទនៅថ្ងៃបុណ្យព្រះយេស៊ូសម្តែងឋានៈព្រះអង្គឲ្យមនុស្សលោកឃើញ **"នេះជាសិទ្ធិរបស់គេ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចូលនៅក្នុងព្រះកាយរបស់ព្រះអង្គ និងទទួលព្រះបន្ទូលជាមរតក ជាសិទ្ធិមនុស្ស"**។ សូមបងស្រីទាំងអស់គិត ដើម្បីរកឃើញផ្លូវថ្មីដើម្បីបន្តប្រកាសដំណឹងល្អដល់មនុស្សដែលស្រេកឃ្លាន ដែលកំពុងទន្ទឹងរងចាំសេចក្តីសង្ឃឹម។ ក្នុងភូមិភាគភ្នំពេញយើងមានអាទិភាពសំខាន់ៗដូចជា **"ការសិក្សា សុខភាព ពលករ ជនពិការ ការពារធម្មជាតិ ណែនាំឲ្យអ្នកក្រីក្រចូលនៅក្នុងសង្គមយ៉ាងសកម្ម អន្តរសាសនា"** ដើម្បីឲ្យយើងចូលនៅក្នុងគ្រប់វិស័យនៃសង្គមបច្ចុប្បន្ននេះ។ កុំឲ្យយើងខ្លាច ទោះបីយើងមានគ្នាតិចតែកុំឲ្យយើងខ្លាចព្រោះថាពេលក្រុមបងស្រីមួយបានបង្កើតមន្ទីរពេទ្យនៅប្រទេសសិង្ហបូរី និងប្រទេសថៃ គឺបងស្រីជាអ្នកកាយដីដើម្បីចាក់គ្រឹះមន្ទីរពេទ្យដោយផ្ទាល់។ មានបងស្រីសម្នាត់បួននាក់ បានមកដល់ប្រទេសវៀតណាមនៅឆ្នាំ១៨៦០ ដោយមិន

ចេះនិយាយភាសាវៀតណាមទៀត តែបងស្រីអាចប្រមូលយុវនារីនៅទីនោះដើម្បីចូលក្នុងក្រុមដូនជីសម្ងាត់បាន។ ធ្វើយ៉ាងណា ដើម្បីឲ្យអំណរសប្បាយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅជាអំណរសប្បាយរបស់បងស្រី ព្រោះថាកន្លែងណាមានបព្វជិតបព្វជិតាកន្លែងនោះមានអំណរសប្បាយ។

ម្សិលមិញអត្ថបទទីមួយនិយាយថា "**បងប្អូនយើងត្រូវការសម្រាកនៅក្នុងព្រះជាម្ចាស់**" ដើម្បីឲ្យបងស្រីទៅមុនបាន ឲ្យបងស្រីយកចិត្តទុកដាក់សម្រាកនៅក្នុងព្រះជាម្ចាស់។ ព្រះជាម្ចាស់បានធ្វើការច្រើន នៅថ្ងៃទី៧ព្រះជាម្ចាស់បានសម្រាក់ ហើយព្រះជាម្ចាស់បានអញ្ជើញយើងឲ្យយើងចូលនៅក្នុងការសម្រាករបស់ព្រះអង្គ ដើម្បីទៅជាតែមួយជាមួយព្រះជាម្ចាស់ពិតមែន។ ព្រះជាម្ចាស់ជាប្រភពនៃគ្រប់សកម្មភាពរបស់យើង និងព្រះជាម្ចាស់ជាកម្លាំងដើម្បីឲ្យសកម្មភាពទាំងនោះទៅមុខបាន។ ឲ្យយើងនឹកឃើញព្រះជាម្ចាស់ នឹកឃើញដល់ព្រះនាងម៉ារី ដែលធ្វើដំណើរជាមួយយើងដោយយើងសម្រាកនៅក្នុងព្រះជាម្ចាស់ ដោយសារយើងជាធ្លុងតែមួយនៅក្នុងព្រះគ្រីស្ត យើងជាធ្លុងតែមួយនៅក្នុងក្រុមបងស្រី។ ឲ្យបងស្រីបងប្រុសទាំង២៧ក្រុម ជួយលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយដឹងថាយើងជាក្រុមតែមួយជាបព្វជិតបព្វជិតា យើងត្រូវការលើកទឹកចិត្តគ្នាទៅវិញទៅមកទោះយើងជាបរទេសឬខ្មែរក៏ដោយ។ ជាពិសេសសម្រាប់បងស្រីថ្មី ដើម្បីទទួលកម្លាំអក្នុងក្រុមផ្ទាល់ខ្លួន និងទទួលកម្លាំងពីគ្នាទៅវិញទៅមក ជាមូលហេតុរាល់ថ្ងៃទី៧មករា យើងមានកម្មវិធីឲ្យបព្វជិតបព្វជិតាជួបជុំគ្នា ដើម្បីធ្វើដូចម្ដេចឲ្យយើងលើកទឹកចិត្តគ្នាទៅវិញទៅមក។ ក្នុងភូមិភាគភ្នំពេញ មានក្រុមខ្លះមានបងស្រីច្រើន មានក្រុមខ្លះមានបងស្រីតិច ដូច្នេះឲ្យយើងលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យព្រះសហគមន៍របស់យើងមានជីវិត ដោយដឹងថាកន្លែងណាមានបព្វជិតបព្វជិតា កន្លែងនោះមានអំណរសប្បាយរបស់ព្រះជាម្ចាស់ ដើម្បីបម្រើព្រះសហគមន៍ ដើម្បីបម្រើមនុស្សលោក។ អាម៉ែន។